# មេរៀនទី៦៖ ព្រះបន្ទូលគឺជាព្រះ

## យ៉ូហាន ១៖១-១៨

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/7UjC48_z8Mo

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/vuC330xDLMw

**គោលបំណង៖** ព្រះអង្គតែងគង់នៅជាមួយយើងជានិច្ច

**ខគម្ពីរចងចាំ៖** *១យ៉ូហាន៖១ "កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. បើទ្រង់គង់ជាមួយ https://youtu.be/2CzIW4_ueg0
២. ព្រះយេស៊ូវគឺជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo
៣. ខ្ញុំនិងទុកចិត្តទ្រង់ https://youtu.be/WCZlwlstAzc

**១ អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត «តើអ្នកឃើញអ្វី?» ( ព្រះតែងតែគង់ជាមួយយើង )**

សំភារៈដែលត្រូវការ៖ ទឹកមួយពែងធំលាយជាមួយក្រូចឆ្មារ( លាយឲ្យជូរ ) និងពែងតូចៗសំរាប់ កុមារភ្លក្ស។



ក. បង្ហាញពែងទឹក (មានទឹកក្រូចឆ្មារនៅខាងក្នុង) ហើយសួរកុមារ តើពួកគេឃើញអ្វីខ្លះ? កុមារនឹងឆ្លើយ "ទឹក" (ធ្វើយ៉ាងណាកុំឲ្យកុមារដឹងថាមានទឹកក្រូចឆ្មារនៅក្នុងទឹកនោះ)

ខ. បន្ទាប់មកសុំអ្នកស្ម័គ្រចិត្តមួយចំនួនមកភ្លក្សទឹកនោះ។

គ.សួរកុមារតើទឹកដែលគេផឹកនោះមានរសជាតិអ្វី?ពួកគេនឹងឆ្លើយថា "ក្រូចឆ្មារ" ។

ឃ. សូមពន្យល់ប្រាប់កុមារថាទោះជាគេមិនឃើញក្រូចឆ្មារនៅក្នុងទឹកក៏ដោយ តែវានៅក្នុងទឹកនោះ។ ដូចគ្នាដែរ ទោះបីយើងមិនអាចមើលឃើញព្រះនៅពីមុខយើងក៏ដោយ ក៏ព្រះតែងតែគង់នៅទីនោះជានិច្ច។

**៤. ការណែនាំមេរៀន**

តើប្អូនកំពុងស្នាក់នៅក្នុងផ្ទះជាមួយនរណាខ្លះរាល់ថ្ងៃនេះ?( ទុកឲ្យកុមារឆ្លើយ ) តើប្អូនមានអារម្មណ៍បែបណានៅពេលពួកគាត់នៅជាមួយប្អូនៗ?( ទុកឲ្យកុមារឆ្លើយ )

ថ្ងៃនេះអ្នកគ្រូចង់ប្រាប់ប្អូនៗថា ទោះបីជាប្អូនមិនមានឪពុកម្ដាយ បងប្អូន ឬសាច់ញាតិ នៅជាមួយក៏ដោយ ក៏ប្អូននៅតែមានម្នាក់ដែលតែងតែនៅជាមួយនឹងប្អូនជានិច្ច។ តើប្អូនដឹងទេថាគាត់ជាអ្នកណា? តោះយើង នឹងរៀនពីបុគ្គលម្នាក់នោះនៅក្នុងព្រះគម្ពីរជាមួយគ្នា។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃនេះយើងនឹងរៀនអំពីព្រះអង្គទ្រង់គង់ជាមួយយើង។ ប្រសិនបើយើងអានព្រះគម្ពីរ **យ៉ូហាន ១៖១** បានចែងថា "កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូល នោះឯងជា "ព្រះ" កាលពីដើមដំបូងឡើយតើ "ព្រះបន្ទូល" ជាអ្នកណា? ព្រះគម្ពីរបានប្រាប់ថា "ព្រះបន្ទូល" នៅ ជាមួយនឹងព្រះហើយ "ព្រះបន្ទូល" នោះជាព្រះ!

ក្នុងគម្ពីរ **យ៉ូហាន ១៖១៤** បាននិយាយថា "ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា" គឺមានន័យថា "ព្រះបន្ទូល" គឺជាព្រះយេស៊ូវ។ បើទោះបីទ្រង់ជាព្រះក៏ដោយក៏ ព្រះយេស៊ូវបានយាងមកយកកំណើតជាមនុស្សដូចជាពួកយើងដែរ ។ ព្រះយេស៊ូវជាព្រះ ប៉ុន្តែជំនួសឲ្យការ រស់នៅលើឋានសួគ៌ ព្រះអង្គបានយាង ចុះមករស់នៅជាមួយយើងវិញ! ទ្រង់ធ្វើបែបនេះដើម្បីជួយសង្គ្រោះ យើងនិងរំលឹកយើងថាព្រះអង្គតែងតែគង់នៅជាមួយយើងជានិច្ច។

ព្រះអង្គចង់ឲ្យយើងជឿដោយគ្មានការសង្ស័យថា ទ្រង់គង់ជាមួយយើង។ នៅពេលដែលយើងទុកចិត្តថាព្រះអង្គគង់ជាមួយយើង នោះអ្វីៗនឹងត្រលប់ទៅជាមានផ្លូវដោះស្រាយហើយនៅចុងបញ្ចប់នឹងប្រែទៅជារឿងល្អឡើងវិញ ទោះបីជាបញ្ហាទាំងនោះមើលទៅដូចជាមិនសូវល្អក៏ដោយ ទាំងនេះគឺដោយសារយើងមានកំឡាំងពីព្រះជាម្ចាស់។ បើទោះបីជាយើងមិនអាចមើលព្រះឃើញដោយភ្នែករបស់យើងក៏ដោយ តែយើងអាចដឹងថាព្រះអង្គគង់នៅជាមួយយើងតាមរយៈការឆ្លើយតបរបស់ទ្រង់នៅពេលយើងអធិស្ឋាន ។ ជួនកាលយើងអាចទទួលនូវអារម្មណ៍ពីក្តីស្រឡាញ់ និងវត្តមានរបស់ព្រះ ហើយជួនកាលក៏យើងមិនមានអារម្មណ៍ទាំងនោះដែរ។ យើងអាចមានអារម្មណ៍ថាយើងដូចជានៅតែម្នាក់ឯង នៅពេលយើងភ័យខ្លាចបាក់ទឹកចិត្ត មានជំងឺ ត្រូវមិត្តភក្តិ ឬឪពុកម្តាយបោះបង់ចោល។ ឬក៏អាចជាពេលដែលគ្រូរបស់យើង មិនបានយកចិត្តទុកដាក់ជាមួយយើង ដែលធ្វើឲ្យយើងមានអារម្មណ៍ថាគ្មានអ្នកណាម្នាក់អាចជួយយើងបានឡើយ ។ គ្រប់ពេលដែលមានបញ្ហាទាំងនោះគឺជាពេល ដែលយើងត្រូវតែមានជំនឿថាព្រះអង្គទ្រង់គង់ជាមួយយើង ពីព្រោះទ្រង់បានសន្យាថា ទ្រង់នឹងគង់ជាមួយយើងគ្រប់ពេល។

សូមគិតពីពេលវេលាដែលព្រះបានយកចិត្តទុកដាក់ចំពោះអ្នក ទោះបីជាអ្នកមិនអាចមើលឃើញទ្រង់ក៏-ដោយ។ ព្រះអង្គតែងតែគង់ជាមួយយើង ហើយទ្រង់នឹងតែងតែមើលថែយើង។

## ៦. សំនួរពិភាក្សា

១. តើនៅក្នុងគម្ពីរ **យ៉ូហាន ១៖១** បាននិយាយថាព្រះបន្ទូលជាអ្វី? (*ជាព្រះ*)

២. តើនៅក្នុងគម្ពីរ **យ៉ូហាន ១៖១៤** បាននិយាយថាមានអ្វីកើតឡើងចំពោះព្រះបន្ទូល?
(ព្រះបន្ទូលបានត្រឡប់ទៅជាសាច់ឈាម *ហើយគង់នៅជាមួយយើង*)

៣. តើនៅពេលណាដែលអ្នកមានអារម្មណ៍ថាដូចជាព្រះកំពង់គង់ជាមួយអ្នក?
(*សូមឲ្យកុមារឆ្លើយ*)

៤. តើអ្នកគួរធ្វើអ្វីខ្លះ នៅពេលដែលអ្នកមានអារម្មណ៍ថាឯកាហើយគ្មាននរណាម្នាក់ជួយអ្នក?
*(ច្រៀង អានគម្ពីរ និងអធិស្ឋានទៅកាន់ព្រះ សូមចាំព្រះអង្គបានសន្យាថាទ្រង់តែងតែគង់ជាមួយយើង)*

## ៧. ល្បែងកំសាន្ត

- **ជំរើសទី១ « បើកភ្លើង និងបិទភ្លើង»**




ព្រះយេស៊ូវមានបន្ទូលថា ព្រះអង្គគឺជាពន្លឺនៃលោកីយ៍។ សូមពន្យល់ប្រាប់កុមារថា ពេលភ្លើងបើកពួកគេអាចរាំបាន ពីព្រោះវាជាសញ្ញាប្រាប់ថា ព្រះយេស៊ូវគង់ជាមួយពួកគេ។ ប៉ុន្តែនៅពេលដែលភ្លើងបិទ ពួកគេត្រូវតែបញ្ឈប់ការរាំរបស់ពួកគេ បើសិនពួកគេនៅតែបន្តរាំ គឺពួកគេចាញ់ល្បែងនេះ។

- **ជំរើសទី២ «បិទភ្នែក និងបើកភ្នែក»**



ប្រសិនបើនៅក្នុងព្រះវិហារមិនមានភ្លើង អ្នកក៏អាចឲ្យក្មេងលេងល្បែងនេះបានដូចគ្នា ដោយឲ្យកុមាររាំនៅពេលគេបើកភ្នែក ហើយឲ្យពួកគេឈប់រាំនៅពេលគេបិទភ្នែក។

## ៨. ខគម្ពីរចងចាំ

***យ៉ូហាន ១:១*** *"កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ។"*

## ៩. **ហាត្ថកម្ម** ឲ្យកុមារផាត់ពណ៌លើរូបភាពដែលមានខគម្ពីរចងចាំ

## ១០. ចំរៀង

( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូៈ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
កុមារអាចនឹងត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលយកគំនិតដែលថាព្រះទ្រង់គង់នៅជាមួយយើង។ ប៉ុន្តែដោយសារនេះគឺជា គំនិតតាមបែបអរូបី ដែលធ្វើឲ្យកុមារពិបាកយល់បានថា តើព្រះជាម្ចាស់ពិតជាបានគង់ជាមួយនឹងយើងពិតមែនតាមរបៀបណា។ ក្នុងនាមយើងជាគ្រូម្នាក់ អ្នកគួរតែត្រៀមខ្លួនជាស្រេចដើម្បីប្រាប់កុមារៗពីបទពិសោធន៍ផ្ទាល់ខ្លួនមួយចំនួនរបស់អ្នកអំពី របៀបដែលព្រះគង់ជាមួយអ្នក។ សូមស្វែងរកវិធីណាដើម្បីឲ្យអ្នកអាចចែករំលែកពីសាច់រឿងរបស់អ្នកទៅកាន់សិស្សក្នុងម៉ោងបង្រៀនណាមួយ និងត្រូវស្វែងរកឱកាសដើម្បីធ្វើយ៉ាងណាឲ្យកុមារអាចចែករំលែកបទពិសោធន៍របស់ពួកគេ វិញផងដែរ។ សូមអរគុណសំរាប់ការបង្កើតនូវបរិយាកាសកក់ក្តៅនៅក្នុងថ្នាក់រៀន ដើម្បីលើកទឹកចិត្ត កុមារឲ្យចែកចាយសាច់រឿង របស់ពួកគេ។ ការនេះនឹងប្រទានពរចំពោះសេចក្តីជំនឿដល់កុមារ ដែលអ្នកកំពុងតែបង្រៀន និង ដឹកនាំពួកគេ។

# ផាត់ពណ៌


យ៉ូហាន ១៖១
កាលដើមដំបូងមានព្រះបន្ទូល
ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ
ហើយព្រះបន្ទូលនោះ ឯងជាព្រះ។